# សុន្ទរកថា
# របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, និង ជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល
# ថ្លែងក្នុង
# ពិធីប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ «យុទ្ធសាស្ត្រ ស្តីពីការ-អភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨»

**រាជធានីភ្នំពេញ, ថ្ងៃ ពុធ ១១ រោច, ខែ ចេត្រ, ឆ្នាំម្សាញ់, សប្តស័ក ព.ស ២៥៦៨**
**ត្រូវនឹងថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០២៥ វេលាម៉ោង ៩:០០ នាទីព្រឹក, ហៃយ៉ាត់ រីជិនស៊ី**

*****+*****

- ឯកឧត្តម **ហ៊ុន ម៉ានី**, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ, និង ជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ;
- ឯកឧត្តម **ជា វ៉ាន់ដេត**, រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍, និង ជាប្រធានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល;
- ឯកឧត្តម **ឌិត ទីណា**, រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ;
- ឯកឧត្តម **នេត្រ ភក្ត្រា**, រដ្ឋមន្ត្រី ក្រសួងព័ត៌មាន;
- ឯកឧត្តម, លោកជំទាវ, ជាថ្នាក់ដឹកនាំ និង តំណាងក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាល;
- ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកា នៃអង្គពិធី, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំមានកិត្តិយសដ៏ឧត្តុង្គឧត្តម និង សេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានទទួលបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់បំផុត ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតី ក្នុងពិធីប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ **«យុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨»** ។ ក្នុងឱកាសដ៏វិសេសនេះ, ខ្ញុំសូមសម្តែងនូវការស្វាគមយ៉ាងកក់ក្តៅ ចំពោះ **ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកា នៃអង្គពិធី** ដែលបានឆ្លៀតពេលដ៏មានតម្លៃ ចូលរួមក្នុងពិធីដ៏មានសារៈសំខាន់ នាព្រឹកនេះ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះ **ឯកឧត្តម ហ៊ុន ម៉ានី**, **ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ និង ជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**, និង **ឯកឧត្តម ជា វ៉ាន់ដេត**, **រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង ជាប្រធានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល**, ដែលបានថ្លែងសុន្ទរកថាចំណាប់អារម្មណ៍ ប្រកបដោយអត្ថន័យ ដ៏ជ្រាលជ្រៅ នៅមុននេះបន្តិច ។ ខ្ញុំក៏សូមអរគុណដល់ **ឯកឧត្តម គង់ ម៉ារី**, រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, ដែលបានរាយការណ៍យ៉ាងលម្អិត អំពីការរៀបចំ **«យុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨»**, ចាប់តាំងពីកិច្ចដំណើរការនៃការរៀបចំ, ក្របខណ្ឌរួមនៃយុទ្ធសាស្ត្រ, និង តួនាទីរបស់ក្រសួង-ស្ថាប័ន ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ឲ្យបានជោគជ័យ តាមការរំពឹងទុក ។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

បច្ចេកវិទ្យាឌីជីថល, ជាពិសេស វឌ្ឍនភាពចុងក្រោយនៃបញ្ញាសិប្បនិម្មិត ឬ ហៅកាត់ជាភាសាអង់គ្លេសថា «AI» បានក្លាយជាផ្នែកមួយដ៏សំខាន់នៃការរស់នៅ, ការរៀនសូត្រ, ការប្រកបអាជីវកម្ម និង ការផ្តល់សេវាសាធារណៈ ជូនធុរជន ក៏ដូចជា ជូនប្រជាជនទូទៅ ក្នុងយុគសម័យនេះ ដែលជាការណ៍មិនអាចខ្វះបាន ។ ក្នុងន័យនេះ, បច្ចេកវិទ្យាឌីជីថលបានចាក់ស្រេះ ក្នុងគ្រប់សកម្មភាពសង្គម-សេដ្ឋកិច្ច, ហើយបានក្លាយជាកាតាលីករដ៏សំខាន់ក្នុងការជំរុញកំណើន និង ការពង្រឹងភាពធន់នៃសេដ្ឋកិច្ច ដែលមិនអាចមើលរំលងបាន ។

សម្រាប់វិស័យឯកជន, ការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល គឺជាឧត្តមភាពមួយថ្មី ដែលជួយលើកកម្ពស់ប្រសិទ្ធភាពការងារ, កាត់បន្ថយថ្លៃដើម, តភ្ជាប់ខ្សែច្រវាក់ផលិតកម្ម និង ធានានូវភាពប្រកួតប្រជែង ក្នុងទីផ្សារ ។ ដូចគ្នានេះដែរ, ចំពោះវិស័យសាធារណៈ, បច្ចេកវិទ្យាឌីជីថល ក៏បាន និង កំពុង ដើរតួនាទីជាគន្លឹះដ៏សំខាន់ ក្នុងការជំរុញការកែទម្រង់នានា នៅកម្ពុជា, ជាពិសេស ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ដើម្បីកាត់បន្ថយភាពស្មុគស្មាញ នៃការិយាធិបតេយ្យ, បង្កើនប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ, ពង្រឹងអនុលោមភាព និង កែលម្អបរិយាកាសធុរកិច្ច នៅកម្ពុជា ឲ្យកាន់តែប្រសើរឡើង សំដៅឆ្លើយតបទៅនឹងតម្រូវការ, សំណូមពរ និង បំណងប្រាថ្នា របស់ប្រជាជន និង ធុរជន ។

សម្រាប់កម្ពុជា, ការអភិវឌ្ឍវិស័យឌីជីថល ត្រូវបានចាត់ទុកជាចលករដ៏សំខាន់មួយ ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាល សម្រាប់ នីតិកាលទី ៦ នៃរដ្ឋសភា, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និង ភាពប្រាកដនិយម របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្នជា ប្រធានព្រឹទ្ធសភា**, បានប្រកាសដាក់ឲ្យអនុវត្ត នូវ «**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**» និង «**គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥**», ដែលជាឯកសារគោលនយោបាយរយៈពេលវែង សម្រាប់ធ្វើជាត្រីវិស័យ ក្នុងការរៀបចំបរិវត្តកម្មឌីជីថល របស់កម្ពុជា ។ ការដាក់ចេញនូវឯកសារដ៏មានសារៈសំខាន់ទាំងពីរនេះ ក៏បានសបញ្ជាក់ច្បាស់ ពីឆន្ទៈមោះមុត និង ភាពបុរេសកម្ម របស់រាជរដ្ឋាភិបាល ក្នុងការប្តេជ្ញាជំរុញការអភិវឌ្ឍវិស័យឌីជីថលនៅកម្ពុជា ឲ្យកាន់តែមានភាពរស់រវើក ។

សម្រាប់ នីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាល, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ស្វាហាប់, ឈ្លាសវៃ និង ប៉ិនប្រសប់ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី ១** ដើម្បី **កំណើន**, **ការងារ**, **សមធម៌**, **ប្រសិទ្ធភាព**, **និង ចីរភាព**, ដោយបានកំណត់យក **អាទិភាពគន្លឹះ ៥** រួមមាន អាទិភាពគន្លឹះចំនួន ៤ បន្តពី **យុទ្ធសាស្ត្រចតុកោណ** នោះគឺ៖ «**មនុស្ស**, **ផ្លូវ**, **ទឹក** និង **ភ្លើង**; និង អាទិភាពគន្លឹះបន្ថែមថ្មីមួយទៀត, ពោលគឺ **បច្ចេកវិទ្យា**, ជាពិសេស **បច្ចេកវិទ្យាឌីជីថល**, ដើម្បីឆ្លើយតប

ប្រកបដោយសង្គតិភាព ទៅនឹង «**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**» និង «**គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥**» ។

ក្នុងបរិការណ៍ដែលកម្ពុជា កំពុងស្ថិតនៅលើមាគ៌ានៃការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល ដែលរឹងមាំ, មានបរិយាបន្ន និង មានភាពប្រកួតប្រជែងខ្ពស់, រាជរដ្ឋាភិបាល បន្តប្ដេជ្ញាធ្វើឲ្យបរិយាកាសធុរកិច្ចនៅកម្ពុជា មានលក្ខណៈកាន់តែប្រសើរឡើងជាលំដាប់ ។ ការប្រែក្លាយទៅជារដ្ឋាភិបាលឌីជីថល ក្នុងជំហានដំបូង តាមរយៈការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក មិនមែនជាជម្រើស សម្រាប់ការពិចារណាទៀតទេ, ប៉ុន្តែ ជាការចាំបាច់ ដែលត្រូវតែអនុវត្តឲ្យបានជោគជ័យ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និង ភាពជឿទុកចិត្ត ពីសំណាក់ប្រជាពលរដ្ឋ និង វិស័យឯកជន ។ ក្នុងន័យនេះ, ការធ្វើទំនើបកម្មការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ត្រូវបានចាត់ទុកជាអាទិភាពខ្ពស់មួយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានបន្តអនុវត្តជាប្រចាំ ចាប់ពីនីតិកាលទី ៦ នៃរដ្ឋសភា រហូតដល់បច្ចុប្បន្ន និង តទៅអនាគត ។ ជាក់ស្តែង, រាជរដ្ឋាភិបាល បានរៀបចំ និង ដាក់ឲ្យដំណើរការ នូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន តាំងពីឆ្នាំ ២០២០ ដែលបានអនុញ្ញាតឲ្យធុរជន ចុះបញ្ជីអាជីវកម្មជាកញ្ចប់ ដោយបានកាត់បន្ថយភាពស្មុគស្មាញជាច្រើន ក្នុងជំហានដំបូងនៃវដ្តធុរកិច្ច ។

ដើម្បីដំណើរការអាជីវកម្មស្របច្បាប់, ធុរជនមានកាតព្វកិច្ចបំពេញអនុលោមភាព ដោយត្រូវស្នើសុំលិខិតអនុញ្ញាត ឬ អាជ្ញាបណ្ណពាក់ព័ន្ធនានា ផ្អែកតាមសកម្មភាពអាជីវកម្មនីមួយៗ ដែលអាចពាក់ព័ន្ធ និង ប្រទាក់ក្រឡាគ្នា ជាមួយក្រសួង-ស្ថាប័នជាច្រើន, ទាំងក្នុងទិដ្ឋភាពនៃនីតិវិធីស្នើសុំសេវា និង មធ្យោបាយផ្តល់សេវា ។ ដើម្បីកាត់បន្ថយនូវភាពស្មុគស្មាញនេះហើយ, ទើបរាជរដ្ឋាភិបាល បានដាក់ឲ្យដំណើរការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដោយប្រើប្រាស់យន្តការផ្លាស់ប្តូរទិន្នន័យ តាមថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ឬ ហៅកាត់ជាភាសាអង់គ្លេសថា CamDX, ដែលបានបង្កើតមូលដ្ឋានជាសារវន្ត និង ជាគំរូនៃការផ្តល់សេវាសាធារណៈ សម្រាប់ធុរកិច្ចតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីផ្តល់មធ្យោបាយងាយស្រួល សម្រាប់ការស្នើសុំបង្កើតអាជីវកម្ម ឬ អាចនិយាយដោយសាមញ្ញថា ជាការបង្កើតអត្តសញ្ញាណកម្មសហគ្រាស ឬ ក្រុមហ៊ុន ព្រមទាំង បន្ថែមនូវការផ្តល់អាជ្ញាបណ្ណ និង លិខិតអនុញ្ញាតមួយចំនួនទៀត តាមប្រភេទ

សកម្មភាពអាជីវកម្ម ។ ទោះយ៉ាងនេះក្តី, វឌ្ឍនភាពនៃការផ្តល់សេវាសាធារណៈ សម្រាប់ធុរកិច្ច នៅមានកម្រិតនៅឡើយ ដោយសារកត្តាជាសត្យានុម័តមួយចំនួន រួមមាន៖ **ទី១).** ភាពស្មុគស្មាញនៃការផ្តល់សេវា និង នីតិវិធីនៃការស្នើសុំសេវាសម្រាប់ធុរកិច្ច; **ទី២).** កង្វះស្តង់ដា និង គោលការណ៍ណែនាំបច្ចេកទេសរួម សម្រាប់រៀបចំការផ្តល់សេវាតាមអេឡិចត្រូនិក; **ទី៣).** ភាពមានកម្រិតក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលរួម ដែលមានស្រាប់ ជាអាទិ៍៖ ថ្នាល CamDigiKey, CamDX, Bakong និង Verify.gov.kh; **ទី៤).** កង្វះការរៀបចំ និង ការចែករំលែកទិន្នន័យគោល នៅតាមក្រសួង-ស្ថាប័ន; **ទី៥).** កង្វះការរៀបចំក្រមប្រតិបត្តិរួម នៃការផ្តល់សេវា និង កង្វះការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ។ល។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ដើម្បីដោះស្រាយបញ្ហាខាងលើនេះ ជាកញ្ចប់ និង ចូលរួមកែលម្អបរិយាកាស នៃការធ្វើធុរកិច្ចនៅកម្ពុជា, រាជរដ្ឋាភិបាល សម្រាប់ នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការ-ដឹកនាំ ប្រកបដោយគតិបណ្ឌិត និង ចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា,** បានដាក់ចេញ នូវ «**យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨**» ។ យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើង ក្នុងស្មារតីនៃការកែទម្រង់ស៊ីជម្រៅ លើការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ស្របតាមអភិក្រម «**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**» ដោយផ្តោតសំខាន់លើទិដ្ឋភាព ចំនួន ២ គឺ៖ **ទី១).** ការពិនិត្យ និង ការកែសម្រួលឡើងវិញ នៃកម្រៃសេវា និង ការលុបចេញ ឬ ការផ្តួបចូលគ្នា នូវនីតិវិធីនៃការស្នើសុំ ឬ ការផ្តល់សេវាសាធារណៈ នៅតាមក្រសួង-ស្ថាប័ន ដែលមិនមានតម្លៃបន្ថែមខ្ពស់ ឬ មានលក្ខណៈប្រហាក់ប្រហែលគ្នា, និង **ទី២).** ការរៀបចំមធ្យោបាយផ្តល់សេវា តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានស្តង់ដារួម និង មានអន្តរប្រតិបត្តិការជាមួយគ្នា ក្នុង «**ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច**» តែមួយ ។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ, ខ្ញុំក៏សូមគូសរំលេចផងដែរថា ការរៀបចំ «**យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨**» នេះ គឺជាការឆ្លើយតបទៅនឹងការណែនាំដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ក្នុង **វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩** កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០២៣, ហើយក៏ជាការបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ របស់រាជរដ្ឋាភិបាល ក្នុងការបន្តគាំទ្រ, ការជំរុញ និង ការអភិវឌ្ឍ វិស័យឯកជននៅកម្ពុជា តាមរយៈការបង្កើត «**ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច**» មួយដ៏រឹងមាំ ដែលបំពេញគ្នាទៅវិញទៅមក និង មានលក្ខណៈរស់រវើក សម្រាប់ការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច សំដៅគាំទ្រដល់ការបង្កើតបរិយាកាសអំណោយផល ក្នុងការធ្វើធុរកិច្ចនៅកម្ពុជា ស្របតាម **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**, និង **គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥** ។

ការអនុវត្តយុទ្ធសាស្ត្រនេះ ស្ថិតនៅក្រោមការសម្របសម្រួល របស់ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, និង ការធ្វើសមកាលកម្មជាមួយកម្មវិធីគោលនយោបាយពាក់ព័ន្ធវិស័យឌីជីថល និង ការកែទម្រង់រដ្ឋបាលសាធារណៈ, ក្រោមការសម្របសម្រួល របស់គណៈកម្មាធិការ ចំនួន ៣ គឺៈ គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល, និង គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ។ ខ្ញុំមានក្តីរំពឹងខ្ពស់ថា ការដាក់ចេញ និង ការអនុវត្តយុទ្ធសាស្ត្រនេះ ឲ្យសម្រេចបានជោគជ័យ តាមការរំពឹងទុក នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការបង្កើតបរិយាកាសល្អ សម្រាប់ធុរកិច្ច សំដៅបង្កើនភាពធន់នៃសេដ្ឋកិច្ចកម្ពុជា ក្នុងបរិការណ៍ដែលសេដ្ឋកិច្ច តំបន់ និង សកលលោក កំពុងប្រឈមនឹងភាពមិនច្បាស់លាស់កាន់តែខ្លាំងឡើង ។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

«យុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨» បានកំណត់គោលដៅ «**ដាក់ឲ្យដំណើរការ តាមប្រព័ន្ធអេឡិចត្រូនិក នូវសេវាអាទិភាព រហូតដល់ ៨០%, ជាប្រភេទសេវា ដែលមានតម្រូវការខ្ពស់ និង មិននីតិវិធីស្មើស្មុគស្មាញ,**

**នៅត្រឹមដំណាច់ឆ្នាំ ២០២៨»** ។ ដូច្នេះ, ដើម្បីសម្រេចបានគោលដៅ ប្រកបដោយមហិច្ឆតានេះ, គ្រប់តួអង្គពាក់ព័ន្ធទាំងអស់, រួមបញ្ចូលនូវក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលជាអ្នកផ្តល់សេវា ក៏ដូចជា វិស័យឯកជន ដែលជាអ្នកទទួលសេវា, ចាំបាច់ត្រូវចូលរួម ប្រកបដោយភាពសកម្ម និង បុរេសកម្ម ព្រមទាំងស្មារតីទទួលខុសត្រូវខ្ពស់ ជាមួយឆន្ទៈនយោបាយមុតស្រួច ឥតរាថយ ។

ក្នុងន័យនេះ, ជាវិភាគទានក្នុងការជួយសម្រួច, ជំរុញ និង តម្រង់ទិសដៅការងារជាអាទិភាព តទៅមុខ សំដៅជំរុញការអនុវត្តយុទ្ធសាស្ត្រនេះ ឲ្យទទួលបានជោគជ័យ, ខ្ញុំសូមលើកឡើងនូវអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

**ទី១.** ក្រសួង-ស្ថាប័ន ត្រូវសហការជិតស្និទ្ធ ជាមួយគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ក៏ដូចជា គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការធ្វើអាទិភាវូបនីយកម្មសេវាសាធារណៈ ដើម្បីបញ្ចូលជាសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច និង ត្រូវពិនិត្យឡើងវិញ នូវសេវាពាក់ព័ន្ធទាំងឡាយ ក្នុងគោលដៅកែសម្រួលនីតិវិធីស្នើសុំសេវា, កែសម្រួលកម្រៃសេវា, និង ពិនិត្យលទ្ធភាពលុបចេញ ឬ ផ្គួបចូលគ្នានូវសេវាទាំងឡាយណា ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬ មិនមានតម្លៃបន្ថែមខ្ពស់ ដើម្បីធានាប្រសិទ្ធភាពនៃការផ្តល់ និង ការទទួលសេវា ។

**ទី២.** ក្រសួង-ស្ថាប័ន ត្រូវសហការស្អិតល្មួត ជាមួយលេខាធិការដ្ឋាន នៃក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច និង គណៈកម្មាធិការរដ្ឋបាលកិបាលឌីជីថល ក្នុងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិក តាមគោលការណ៍ណែនាំបច្ចេកទេស ដូចមានចែងក្នុងឧបសម្ព័ន្ធនៃយុទ្ធសាស្ត្រនេះ ក្រោមទម្រង់ **«ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច»** តែមួយ ។

**ទី៣.** ក្រសួង-ស្ថាប័ន ដែលគ្រប់គ្រងទិន្នន័យគោល ត្រូវរៀបចំ និង ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យគោល ព្រមទាំង ចែករំលែកទិន្នន័យគោលទាំងនោះ ក្នុង **«ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច»** តាមរយៈថ្នាល CamDX ដើម្បីកាត់បន្ថយការបញ្ចូលទិន្នន័យដដែលៗ, កាត់បន្ថយការភ្ជាប់ឯកសារតម្រូវដែល

មិនសូវចាំបាច់ និង បង្កើនគុណភាពនៃទិន្នន័យ តាមរយៈការផ្ទៀងផ្ទាត់ទិន្នន័យ ។

**ទី៤.** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ធនាគារជាតិនៃកម្ពុជា ដែលកំពុងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល មានជាអាទិ៍៖ ថ្នាល CamDigiKey, CamDX, Bakong, និង Verify.gov.kh, ត្រូវបន្តពង្រឹង និង ធ្វើទំនើបកម្មថ្នាលឌីជីថលទាំងនេះជាប្រចាំ ដើម្បីគាំទ្រដល់ការតភ្ជាប់ និង អន្តរប្រតិបត្តិការនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សំដៅធានាសុវត្ថិភាព និង ប្រសិទ្ធភាព នៃ **«ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច»**, ហើយក្រសួង-ស្ថាប័ន ត្រូវចូលរួមប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថលទាំងនេះ ជាមូលដ្ឋានក្នុងការរៀបចំសេវាអេឡិចត្រូនិករបស់ខ្លួន ។

**ទី៥.** ក្រសួង-ស្ថាប័ន, ក្រោមការដឹកនាំសម្របសម្រួល របស់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និង គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល, ត្រូវរៀបចំផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីប្រតិបត្តិ ដែលទទួលបន្ទុកផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីពង្រឹងសមត្ថភាព និង ការសម្របខ្លួន របស់មន្ត្រីទទួលបន្ទុក ទៅនឹងនីតិវិធីការងារថ្មី, លើកកម្ពស់គុណភាពសេវា និង បង្កើនភាពជឿទុកចិត្ត ពីសំណាក់វិស័យឯកជន ។ និង

**ទី៦.** ក្រសួង-ស្ថាប័ន ត្រូវចូលរួមរៀបចំ និង ពង្រឹងយន្តការផ្សព្វផ្សាយព័ត៌មាន អំពីសេវាអេឡិចត្រូនិករបស់ខ្លួន ឲ្យបានទូលំទូលាយ ជូនដល់ធុរជន ។ ទន្ទឹមនេះ, **ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច** ត្រូវពង្រឹង និង ពង្រីកមុខងាររបស់ថ្នាល business.gov.kh ដើម្បីសម្រួលដល់ធុរជន ក្នុងការស្វែងរកព័ត៌មាន ពាក់ព័ន្ធនឹងសេវាសម្រាប់ធុរកិច្ច និង ផ្តល់ប្រឹក្សាដល់ធុរជន ដើម្បីងាយទទួលបានអនុលោមភាព លើសកម្មភាពអាជីវកម្មរបស់ខ្លួន ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

មុននឹងបញ្ចប់, ខ្ញុំសូមយកឱកាសដ៏ប្រពៃនេះ សម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅ ជូន **ឯកឧត្តម ហ៊ុន ម៉ានី**, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ, និង ជា

ប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, និង ឯកឧត្តម **ជា វ៉ាន់ដេត**, **រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍, និង ជាប្រធានគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល** ដែលបានផ្តល់ការគាំទ្រ និង ការប្តេជ្ញាចិត្ត ក្នុងការចូលរួមជំរុញការអនុវត្តយុទ្ធសាស្ត្រនេះ ឲ្យសម្រេចបានជោគជ័យ ។ ទន្ទឹមនេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ ចំពោះ **ឯកឧត្តម គង់ ម៉ារី**, រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, ក៏ដូចជា អនុប្រធាន និង សមាជិក-សមាជិកានៃក្រុមការងារ ដែលបានខិតខំរៀបចំយុទ្ធសាស្ត្រនេះ រហូតសម្រេចជាស្ថាពរ និង ត្រូវបានប្រកាស ដាក់ឲ្យអនុវត្តជាផ្លូវការ នាថ្ងៃនេះ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និង ភាគីពាក់ព័ន្ធទាំងឡាយ នឹងចូលរួមអនុវត្តយុទ្ធសាស្ត្រ ដ៏មានសារៈសំខាន់នេះ ឲ្យទទួលបានជោគជ័យពេញលេញ តាមការរំពឹងទុក ក្នុងស្មារតីបុរេសកម្ម និង ការទទួលខុសត្រូវខ្ពស់ ដើម្បីគាំទ្រដល់ការរីកលូតលាស់ របស់វិស័យឯកជន ដែលជាឆ្អឹងខ្នង និង ជាកម្លាំងចលករ នៃសេដ្ឋកិច្ចជាតិ ។

ជាទីបញ្ចប់, ក្នុងឱកាសដ៏នក្ខត្តឫក្ស ប្រពៃថ្លៃថ្លា នៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ, ឆ្នាំម្សាញ់, សប្តស័ក, ព.ស. ២៥៦៩, ដែលទើបចូលមកដល់ ក្នុងពេលថ្មីៗនេះ, ខ្ញុំសូមបួងសួងដល់ទេវតាឆ្នាំថ្មី ប្រោះព្រំពរជ័យ, សិរីមង្គល និង វិបុលសុខ ដ៏បវរមហាប្រសើរ ជូន **ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយស ជាតិ និង អន្តរជាតិ, សមាជិក-សមាជិកានៃអង្គពិធី**, និង សូមលោក-អ្នកទាំងអស់គ្នា បានសមប្រកបតែនឹងពុទ្ធពរ ទាំង ៤ ប្រការ គឺ៖ **អាយុ, វណ្ណៈ, សុខៈ និង ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំមានកិត្តិយស សូមប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នូវ **«យុទ្ធសាស្ត្រ ស្តីពីការ-អភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨»** ចាប់ពីពេលនេះតទៅ ។

*សូមអរគុណ!*